# ទឹកចិត្តមាតាបិតា

(បទកាកគតិ)

ជីវិតកើតមក   វាសនាបានជ្រក   លើទ្វីបលោកិយ
មានឪពុកម្ដាយ   សន្ដោសប្រណី   តាំងពីតូចខ្ចី
ដោយក្ដីប្រោសប្រាណ ។

កបព្រហ្មវិហារ   ទាំងបួននោះជា   ធម៌ដ៏កល្យាណ
បីបាច់កូនស្ងួន   ថែថួនអោយក្សាន្ដ   គ្មានក្ដីរំខាន
ធុញទ្រាន់ម្ដងណា ។

ស្រលាញ់កូនណាស់   ខិតខំបំរុះ   ចិញ្ចឹមរក្សា
ប្រដៅអប់រំ   បន្ទំបញ្ញា   បង្ហាត់ បាទ ចាំ
ឆ្លើយញាតិស្រីប្រុស ។

អោយចេះបន្ទាប   ឫកពាសុភាព   ដឹងត្រូវដឹងខុស
យប់ថ្ងៃលោកថ្លៃ   ប្រដៅបណ្ដុះ   បំពាក់បំផុស
ប្រាប់ផ្លូវសុចរិត ។

កូនដល់វ័យរៀន   ចំណាយធនធាន   មិនហ៊ានរិតត្បិត
សណ្ដោងសណ្ដូន   កូនបណ្ដូលចិត្ត   ដោយក្ដីអាណិត
នាំទៅសាលា ។

ក្ដារឈ្នួន ដីស   កាប៊ូបល្អៗ   សៀវភៅប៉ាកា
ខ្មៅដៃបន្ទាត់   ក្បួនច្បាប់តម្រា   ថែមទាំងថវិកា
សិក្សារាល់ថ្ងៃ ។

ទិញម៉ូតូកង់   ផ្កាប់ផ្គុនផ្ចិតផ្ចង់   ទោះថោកទោះថ្លៃ
ឆាលី វីវ៉ា
អាសង់ចាស់ថ្មី   សេរ៉ូពីរ-បី   តម្លៃទាបខ្ពស់ ។
ទុកជាជំនិះ   អោយកូនបានជិះ   ងាយស្រួលឥតមោះ
បានថ្កើងមុខមាត់   មិនអោយអាប់យស   ពេលចូលចំពោះ
ជួបមិត្តភ័ក្ដិផង ។

សេដ្ឋកិច្ចគ្រួសារ   ដុនដាបយ៉ាងណា   ទ្រាំឥតសៅហ្មង
ប្រឹងប្រែងគ្រប់យ៉ាង   ជួយស្ទួយត្រកង   អោយកូនបានឆ្លង
ជ្រោះអវិជ្ជា ។

កូនធំពេញវ័យ   ពុកម៉ែព្រួយភ័យ   គ្រប់ពេលវេលា
ក្រែងកូនធ្លោយធ្លាក់   ក្នុងផ្លូវពាលា   សេពគប់ប៉ះពារ
នឹងជនខូចខិល ។

នាំអោយរំខាន បង់ទ្រព្យខកប្រាណ ជីវិតវេចរិល
វីវក់កំណាច កោងកាចវអិល ជាជនកំហិល
ដំបៅសង្គម ។

ទោះកូនកល្យាណ មានចិត្តសាមាន្យ ខុសតូចខុសធំ
លោកមានមេត្តា ស្តីថាអប់រំ ហៅឡើងទ្រទំ
មិនយកទោសពៃរ៍ ។

បើកូនមិនស្តាប់ ពុកម៉ែឈឺចាប់ ព្រួយពេញហឫទ័យ
ចង់អោយកូនល្អ ជូនដាក់ពិន័យ វាយដំជេរស្តី
អោយកែមារយាទ ។

លើកដៃវាយបុត្រ ចិន្តារន្ធត់ ទ្រូងរវែងចង្អៀត
អួលណែនខ្លោចចិត្ត មិនចង់បៀនបៀត បណ្តោយក្រែងឃ្លាត
ចាកឆ្ងាយសីលធមិ ។

អាណិតឥតស្បើយ ជេរវាយកូនហើយ អាក់អួលដើម ក
ពួនយំខ្សឹកខ្សួល សោកសៅបន្ត ចង់អោយកូនល្អ
ជេរវាយអោយក្រែង ។

កូនខ្លះមិនដឹង ខំខែងក្រោធខឹង កើតទុក្ខចំបែង
ចោទឪពុក ម្តាយ ថាកាចហួសថ្លែង ការពិតខ្លួនឯង
មិនយល់កំហុស ។

មាតាបិតា មិនដែលនរណា ស្អប់កូនស្រីប្រុស
ព្រោះតែស្រលាញ់ មិនចង់អោយខុស ទើបជួយបណ្តុះ
គំនិតស្មារតី ។

អោយបុត្រពុំងា មានទ្រព្យវិជ្ជា សុខនាលោកិយ
ពេលចូលជំនុំ មានយសរាសី កុំអោយអប្រិយ
អាប់ឱនអាត្មា ។

នាមជាកុលបុត្រ កុំចង់តយុទ្ធ ព្រោះក្នុងគេហា
ក្រែងបាបមកទាន់ ជាន់ផ្ទាច់ទុក្ខា ជីវិតខ្លោចផ្សា
រកសុខពុំបាន ។

ប្រញាប់តបស្នង អោយលោកផុតហ្មង កេរ្តិ៍ឈ្មោះថ្កើងថ្កាន
កូនប្រដៅងាយ ពុកម៉ែសុខសាន្ត ទាំងចិត្តទាំងប្រាណ
ព្រោះបានកូនល្អ ។✍

*(០៩ មករា ២០០៣)*

*ស្វាត សាលឿម*